# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :.........៧៤.........បទ.-ប្រក.....

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ មិនា ឆ្នាំ 2002

## ប្រកាស

## ស្តីអំពីសេវាស្ថាបនាការ ដែនាំនូវសំបុត្រ នូវសារ និងនូវកញ្ចប់ ក្នុងតំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង

### រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា.
- បានឃើញ ព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី ២០-០៧-៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦. ប្រកាសឱ្យប្រើដោយច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ០៥អនក្រ ចុះថ្ងៃទី ០៥ ខែមិនា ឆ្នាំ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ៦៦អនក្រ.បក ចុះថ្ងៃទី ២២-១០-៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ សេចក្តីសំរេចលេខ ១៥៤សសរ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ.
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការផែនការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចុះថ្ងៃទី 04 ខែ មិនា ឆ្នាំ 2002 ស្តីអំពីសេវាទូរគមនាគមន៍សំរាប់ឆ្នាំ 2002 ដែលរៀបចំស្នើឡើងដោយក្រុមការងារដំណាងអង្គភាពជំនាញ.

# ស ំ រេ ច

**ប្រការ ១** : កំណត់តម្លៃស្ថាបនាការ ថែទាំទូរស័ព្ទ ទូរសារ និងទូរពុម្ព សំរាប់តំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង ដូចមានចែងក្នុងតារាងភ្ជាប់មកជាមួយនេះ ។

**ប្រការ ២** : បណ្តាញ សំភារៈស្ថាបនា និងបរិធានទូរស័ព្ទ ជាបន្ទុករ៉ាប់រង និងជាកម្មសិទ្ធិរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ ៣** : ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤** : ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកតាមតួនាទី ភារៈកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ។

**ប្រការ ៥** : ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រ ដ្ឋ ម ន្ត្រី

សូ-ខុន

**កន្លែងទទួល:**
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួង ផែនការ
- ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាពត៌មាន"
- ដូចប្រការ ៤
  "ដើម្បីអនុវត្តន៍"
- ឯកសារ-កាលប្បវត្តិ.

ប្រកាសលេខ ................ បទ.ប្រក/ .......... មិនា ឆ្នាំ 2002 ទំព័រ: 1/3

## តារាងថ្លៃសេវា
## ស្ថាបនាការ ថែទាំទូរស័ព្ទ ទូរសារ ទូរពុម្ព
## ក្នុងតំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង
## អនុវត្តចាប់ពីថ្ងៃទី 01 ខែ មេសា ឆ្នាំ 2002

| ក- ទូរស័ព្ទ ទូរសារ | I- តំបន់ក្រុងភ្នំពេញ | II- តំបន់ខេត្ត-ក្រុង |
|---|---|---|
| **១- ស្ថាបនាការទូរស័ព្ទ ទូរសារ** | | |
| ១.១- ស្ថាបនា-ភ្ជាប់បណ្ដាញថ្មី | | |
| គិតទាំងបរិធាន និងសំភារៈ ........................ | 60$/គ្រឿង | 30$/គ្រឿង |
| ១.២- ប្ដូរប្រព័ន្ធ ឬបណ្ដាញ (Change Over) ........ | 30$/គ្រឿង | 15$/គ្រឿង |
| ១.៣- តម្លើបរិធានភ្ជាប់បំបែក (Parallel)(1) .......... | 25$/គ្រឿង | 15$/គ្រឿង |
| ១.៤- តម្លើងម៉ាស៊ីនទូរសារ(ម៉ាស៊ីនឯកជន)............. | 10$/គ្រឿង | 10$/គ្រឿង |
| ១.៥- ផ្ទេរទីកន្លែង (ក្នុងអាគារ) ........................ | 10$/គ្រឿង | 10$/គ្រឿង |
| ១.៦- ផ្ទេរអាស័យដ្ឋាន .............................. | 30$/គ្រឿង | 15$/គ្រឿង |
| **២- ការផ្ដល់លេខទូរស័ព្ទ** (2)(4)(6) | | |
| ២.១- ផ្ទេរកម្មសិទ្ធិ "កាត់ឈ្មោះ" ........................ | 30$/លេខ | 15$/លេខ |
| ២.២- ផ្ដល់លេខទូរស័ព្ទប្រភេទ "Reversed Signal" | 30$/លេខ | 30$/លេខ |
| ២.៣- ផ្ដល់លេខទូរស័ព្ទប្រភេទ "Hunting Group" | 20$/លេខ | 20$/លេខ |
| ២.៤- ប្ដូរលេខទូរស័ព្ទ ........................ | 30$/លេខ | 20$/លេខ |
| **៣- ប្រាក់ធានាតំកល់ទុកសំរាប់ការប្រើប្រាស់ទូរស័ព្ទ ទូរសារ** (បង់ម្ដង)(3) | | |
| ៣.១- សេវាក្នុងប្រទេស (DDD) ............................ | គ្មាន | គ្មាន |
| ៣.២- សេវាអន្តរជាតិ (IDD) .................. | 150$/លេខ | 100$/លេខ |

**៤- ការស្ថាបនាប្រើប្រាស់បណ្ដោះអាសន្ន រយៈពី (៣)ខែខ្លីបំផុត : គិតសរុប :**

៤.១- អនុវត្តតម្លៃត្រង់ចំណុច ១.១ ស្មើ 50ភាគរយ.

៤.២- តម្លៃសេវាផ្សេងទៀតបើមានដូចត្រង់ចំណុច ១.៣, ២.២, ២.៣ ស្មើ 50ភាគរយ.

៤.៣- ទឹងប្រាក់ធានាត្រង់ចំណុច ៣ ខាងលើ ។

ខ. **ទូរពុម្ព** (TELEX) (5) : **ការស្ថាបនាភ្ជាប់ប្រើប្រាស់នៅក្រុងរាជធានី :**

១. ***តំបន់ក្រុងភ្នំពេញ***

១.១- ស្ថាបនាការទូរពុម្ព (4W) តម្លៃម៉ៅផ្តាច់ (ម៉ាស៊ីនឯកជន) ................ 280$/គ្រឿង

១.២- តម្លើងម៉ាស៊ីនទូរពុម្ព (ម៉ាស៊ីនឯកជន) ................................................ 30$/គ្រឿង

២. ***តំបន់ខេត្ត-ក្រុង*** អនុវត្តតំលៃដោយសារណាការ ( Quotations ) តាមខេត្ត-ក្រុងនិមួយៗ

២-១- តំលៃបរិបថចំណុះ 2.4Kbps (4W)

២.២- តំលៃម៉ៅផ្តាច់ក្នុងក្រុង (ម៉ាស៊ីនឯកជន) ................................................ 280$/គ្រឿង

២.៣- តម្លើងម៉ាស៊ីនទូរពុម្ព (ម៉ាស៊ីនឯកជន)

៣. ***ប្រាក់ធានាតំកល់ទុកសំរាប់ការប្រើប្រាស់ទូរពុម្ព (បង់មុន)*** (3) ............ 150$/គ្រឿង

| គ. **ថ្លៃជួលសេវាប្រចាំខែ** | **តំបន់ក្រុងភ្នំពេញ** | **តំបន់ខេត្ត-ក្រុង** |
|---|---|---|
| ១. **ការប្រើប្រាស់ទូរស័ព្ទ-ទូរសារ** | | |
| ១.១- ជួលជាវនិងថែទាំបណ្តាញ | 7$/លេខ | 4$/លេខ |
| ១.២- បរិធានភ្ជាប់បំបែក | 2$/លេខ | 2$/លេខ |
| ១.៣- លេខទូរស័ព្ទប្រភេទ "Reversed signal " | 3$/លេខ | 3$/លេខ |
| ២. **ការប្រើប្រាស់ទូរពុម្ព** | | |
| ២.១- ជួលជាវនិងថែទាំបណ្តាញក្រៅប្រទេស | 34$/លេខ | |
| ២.២- ជួលជាវនិងថែទាំបណ្តាញក្នុងក្រុង | 20$/លេខ | |
| ២.៣- ជួលជាវនិងថែទាំបណ្តាញក្នុងប្រទេស .......... | 28$/លេខ | |

៣. **ការផ្អាកប្រើប្រាស់បណ្តោះអាសន្ន សេវាទូរស័ព្ទនិងសេវាទូរពុម្ព**

៣.១- អនុញ្ញាតិការផ្អាកបណ្តោះអាសន្នត្រឹមរយៈ3(បី)ខែ គិតថ្លៃ 50% នៃថ្លៃជួលជាវប្រចាំខែ ។

៣.២- ការបង់ថ្លៃជួលជាវសេវាដែលបានប្រើប្រាស់មិនពេញខែ ត្រូវបានគិតតាមចំនួនថ្ងៃប្រើប្រាស់ក្នុងតំលៃ ១/៣០ភាគមួយថ្ងៃនៃថ្លៃជួលជាវប្រចាំខែ ។

៤. **ការផ្តល់វិក័យប័ត្រលំអិតលើការប្រើប្រាស់សេវា** (7)

៤.១- តំបន់ក្រុងភ្នំពេញ : ផ្តល់ប័ណ្ណលំអិតលើសន្ទនាការទូរស័ព្ទប្រចាំខែ ................. 2$/ច្បាប់

៤.២- តំបន់ខេត្ត-ក្រុង : ផ្តល់ប័ណ្ណលំអិតលើសន្ទនាទូរស័ព្ទប្រចាំខែ អាចផ្តល់ជូនដោយឥតគិតថ្លៃ បើមានសំណើផ្ទាល់របស់អតិថិជន ។

ប្រកាសលេខ ................ បទ.ប្រក/ .......... មិនា ឆ្នាំ 2002



**លក្ខណ្ឌនៃការផ្គត់ផ្គង់សេវា :**

(1)- ការស្នាបនា-តម្លើងបរិធានភ្ជាប់បំបែក (Parallel) ត្រូវបានអនុញ្ញាតតាមលក្ខណ្ឌបច្ចេកទេសបាន មួយគ្រឿងក្នុងអាគារតែមួយ សំភារៈផ្គត់ផ្គង់ដោយក្រសួង ។

(2)- លេខទូរស័ព្ទត្រូវបានផ្គត់ផ្គង់ជូនជាកម្មសិទ្ធឯកជន ពុំអាចបំរើសាធារណ:ដោយគ្មានច្បាប់អនុញ្ញាត ។

(3)- ប្រាក់ធានាតំកល់ទុកត្រូវបានបង់ក្នុងគ្រាស្នាបនាការ និងត្រូវដកបង្វែរជូនអតិថិជនវិញ ល្គិកណាបាន សុំបញ្ឈប់ការប្រើប្រាស់សេវាជាស្ថាពរ និងបានធ្វើការទូទាត់ថ្លៃសេវាគ្រប់ចំនួន ។

(4)- ភ្នាក់ងារមានច្បាប់លក់លេខទូរស័ព្ទនៅរាជធានីភ្នំពេញ អាចគិតយកថ្លៃ 30ដុល្លា (30$) និងនៅខេត្ត មួយគ្រឿង 10ដុល្លា (10$) បន្ថែមលើថ្លៃស្នាបនាការគ្រាដំបូង (Installation Fees)ដែលរដ្ឋកំណត់ សំរាប់ការងារសិក្សាទីផ្សារ និងផ្សព្វផ្សាយពាណិជ្ជកម្ម ។

(5)- ការស្នាបនាប្រើប្រាស់សេវាទូរពុម្ព (Telex) ជាបណ្តោះអាសន្នពុំត្រូវបានអនុញ្ញាត ។

(6)- ការផ្លាស់ប្តូរលេខទូរស័ព្ទ ត្រូវធ្វើការទូទាត់បំណុលថ្លៃសេវាជាមុន ។

(7)- វិក័យប័ត្រប្រើប្រាស់សេវាត្រូវបានចេញជូនរៀងរាល់ដំណាច់ខែ នៃប្រតិទិន មានទំរង់ជាតារាងសរុបលើប្រភេទសន្ទនាការ ។ អតិថិជនអាចសុំអោយផ្តល់វិក័យប័ត្រតាមករណីពិសេសដោយត្រូវបង់ថ្លៃបន្ថែម ។